ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តឧត្តរមានជ័យ

លេខៈ ០០២ សជណ.ខជ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ ២០១២

**យោងៈ** សេចក្តីជូនដំណឹងលេខៈ ០០៦ សហវ.អពជ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១២ ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សូមជូនដំណឹងដល់ ឯកឧត្តម-លោកជំទាវ លោក-លោកស្រី ទាំងអស់មេត្តាជ្រាបថា ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ត្រូវចាប់អនុវត្តពីថ្ងៃទី ១៥ ខែ កុម្ភៈ រហូតដល់ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០១២ ដោយមិនគិតថាជារបស់រដ្ឋ រឺ ឯកជនឡើយ ។ ឯការត្រួតពិនិត្យលើការបង់ពន្ធនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១២ តទៅ ។

ដើម្បីបំពេញកាតព្វកិច្ចបង់ពន្ធនេះម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះទាំងអស់ ត្រូវបំពេញលិខិតប្រកាស ចំនួន ២ សន្លឹក (គំរូមានស្រាប់) និង ត្រូវប្រគល់បង្កាន់ដៃឆ្នាំ ២០១១ ដល់មន្ត្រីមានសមត្ថកិច្ច សម្រាប់ជាភស្តុតាងបញ្ជាក់ថា មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះ បានបង់ពន្ធឆ្នាំ ២០១១ រួចហើយ ។

ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះណា ដែលមិនមានបង្កាន់ដៃបង់ពន្ធឆ្នាំ ២០១១ទេ ត្រូវបង់ពន្ធសម្រាប់ ឆ្នាំ ២០១១ និង ត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតអោយបង់ពន្ធសម្រាប់ឆ្នាំ២០១២ ។ ក្នុងករណីបាត់បង្កាន់ដៃបង់ពន្ធឆ្នាំ២០១១ ម្ចាស់មធ្យោបាយដឹកជញ្ជូន និង យានជំនិះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធឆ្នាំ ២០១១ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត នៃទីកន្លែងដែលបានបង់ពន្ធនោះ ។

ក្រោយពេលបង់ពន្ធរួច អ្នកបង់ពន្ធត្រូវទទួលបានបណ្ណបង់ពន្ធ ១ សន្លឹក សម្រាប់បិទជាប់មធ្យោបាយដឹកជញ្ជូន និង យានជំនិះនោះ និង បង្កាន់ដៃបង់ពន្ធ ១ សន្លឹកទៀត ដែលត្រូវរក្សាទុកជាប់ជាមួយ សម្រាប់បង្ហាញដល់មន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច ។ ពន្ធនេះត្រូវបានលើកលែងចំពោះ ៖

១- រថយន្តគិលានសង្គ្រោះ និង រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ ។

២- មធ្យោបាយដឹកជញ្ជូន និង យានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើអោយការងារការពារប្រទេស សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ។

៣- មធ្យោបាយដឹកជញ្ជូន និង យានជំនិះរបស់បេសកកម្មទូត រឺ កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬ ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេស របស់រដ្ឋាភិបាលនានា ។

អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ សង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តម -លោកជំទាវ លោក -លោកស្រី ពិតជាមានការភ្ញាក់រលឹកខ្ពស់ ហើយអញ្ជើញទៅបំពេញកាតព្វកិច្ចបង់ពន្ធនេះ អោយបានរួសរាន់ទាន់ពេលវេលាជាពុំខានឡើយ ។

ឧត្តរមានជ័យ,ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ២០១២

អភិបាលខេត្ត

ប៊ុច_សុខិន

ចំលងជូន :

-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-អគ្គនាយកដ្ឋានពន្ធដារ
-ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
( ដើម្បីគោរពជូនជ្រាប )
-សាខាពន្ធដារខេត្ត
(ដើម្បីអនុវត្ត)
-ស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ខ្សែកាប(ដើម្បីផ្សព្វផ្សាយ)
-ឯកសារ-កាលប្បវត្តិ